**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាធម្មនុញ្ញ**

លេខ : ០៣៣/០២/២០១៣ កបធ.សជណ

រាជធានីភ្នំពេញ ថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១៣

**សូមជម្រាបមក**

**ឯកឧត្តម លោកជំទាវទាំង ១៤ រូប**

**កម្មវត្ថុ** : ករណីស្នើបញ្ជាក់ពីភាពអធម្មនុញ្ញភាពនៃសេចក្តីសម្រេចរបស់គណៈកម្មាធិការអចិន្ត្រៃយ៍នៃរដ្ឋសភាក្នុងការបង្អកប្រាក់បំណាច់តំណាងរាស្ត្រគណបក្ស សម រង្ស៊ី គណបក្ស សិទ្ធិមនុស្សនិងគណបក្ស នរោត្តម រណប្ញទ្ធិ ។

**យោង** : - លិខិតចុះថ្ងៃទី ១៧ ខែមិថុនា ឆ្នាំ២០១៣ របស់ឯកឧត្តម លោកជំទាវទាំង ១៤ រូប
- មាត្រា ៩៥ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- វាក្យខ័ណ្ឌទី១ មាត្រា ១៥ និង មាត្រា ១៦ នៃច្បាប់ស្តីពីគណបក្សនយោបាយ
- វាក្យខ័ណ្ឌទី១ មាត្រា ១២០ ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- ប្រការ ៨៣ ថ្មី នៃបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា
- សេចក្តីសម្រេចលេខ : ១១៣/១៣ គ.ជ.ប.ស.ស.រ ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៣ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបឯកឧត្តម លោកជំទាវថា ក្រុមប្រឹក្សាធម្មនុញ្ញបានទទួលសំណើរបស់ឯកឧត្តម លោកជំទាវ និងបានដាក់ជូនក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យ ពិភាក្សាក្នុងកិច្ចប្រជុំពេញអង្គ ថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១៣ ព្រមទាំងបានសម្រេចដូចតទៅ :

១-ឯកឧត្តម លោកជំទាវទាំង១៤រូប ពុំមានគុណវុឌ្ឍិស្របតាមបទប្បញ្ញត្តិមាត្រា ១៤១ ថ្មី នៃរដ្ឋធម្មនុញ្ញ និងមាត្រា ១៨ ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញទេ ។

២-*កម្មវត្ថុស្នើបញ្ជាក់ពីភាពអធម្មនុញ្ញភាពនៃសេចក្តីសម្រេចរបស់គណៈកម្មាធិការអចិន្ត្រៃយ៍នៃរដ្ឋសភាក្នុងការបង្អកប្រាក់បំណាច់តំណាងរាស្ត្រគណបក្ស សម រង្ស៊ី គណបក្ស សិទ្ធិមនុស្ស និងគណបក្ស នរោត្តម រណប្ញទ្ធិ* មិនស្ថិតក្នុងសមត្ថកិច្ចរបស់ក្រុមប្រឹក្សាធម្មនុញ្ញទេ ។

៣-បញ្ហាពាក់ព័ន្ធដល់មាត្រា ៧៦ និងមាត្រា ៩៥ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ក្រុមប្រឹក្សា-ធម្មនុញ្ញបានបកស្រាយដូចមាននៅក្នុងសេចក្តីសម្រេចលេខ : ០៥៤/០០៥/២០០៣ កបធ.ច ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០០៣ រួចហើយ ។

សូមឯកឧត្តម លោកជំទាវទាំង ១៤ រូបទទួលនូវការរាប់អានអំពីខ្ញុំ ។

ជ.ក្រុមប្រឹក្សាធម្មនុញ្ញ

ប្រធាន

ឯក សំអុល